វិទ្យាស្ថានគរុកោសល្យបាត់ដំបង

Battambang Teacher Education College



កិច្ចការស្រាវជ្រាវក្រុមទី១

# សណ្ឋានដីប្រទេសកម្ពុជា

គ្រូឧទ្ទេសៈសូ វិចិត្រ

ឆ្នាំសិក្សា ២០២៤-២០២៥

1. លាភ សុខជា
2. ឈន លក្ខិណា
3. ម៉ម មរមី
4. ឡុង ស្រីលីស
5. ហាន់វណ្ណ កណ្ណិកា

# អារម្ភកថា

ខ្ញុំបាទ/នាងខ្ញុំ ជាគរុនិស្សិតសិក្សានៅវិទ្យាស្ថានគរុកោសល្យបាត់ដំបងបាន រៀបរៀង និងចងក្រងខ្លឹមសារអត្ថបទទាក់ទងទៅនឹង សណ្ឋានដីប្រទេសកម្ពុជា ក្នុង គោល បំណងដើម្បីពង្រឹងបន្ថែមនូវការអភិវឌ្ឍន៍ចំណេះដឹង ចំណេះធ្វើ បំណិន អាកប្បកិរិយា និងការសាមគ្គីគ្នារបស់គរុនិស្សិតឲកាន់តែប្រសើរឡើង និងមានភាព ស្និតស្នាលគ្នា ជាពិសេសក្នុងការសិក្សានៅវិទ្យាស្ថានគរុកោសល្យបាត់ដំបង ។ ជាមួយគ្នានេះដែលយើងខ្ញុំជា គរុនិស្សិតនៃវិទ្យាស្ថានគរុកោសល្យបាត់ដំបង សូមធ្វើ ការគោរពចំពោះ លោកគ្រូ ដែលបានអនុញ្ញាតឲយើងខ្ញុំបានសរសេរនូវអត្ថបទនេះ ឡើងដើម្បីចែករំលែកនូវ ចំណេះដឹងទុកជាឯកសារដល់អ្នកសិក្សា និងជាឯកសារ ស្រាវជ្រាវបន្ថែមទៀតដែល អាចឲគរុនិស្សិតមានសមត្ថភាពយល់  ដឹង ស្គាល់  ពីភូមិ សាស្ត្រ នៃទឹកដីរបស់ខ្លួន ។

ទោះបីជាយ៉ាងណាក៏ដោយកយើងខ្ញុំនៅតែគិតថាវានឹងកើតមាននូវកំហុសឆ្គង ដោយ

អចេតនាជាមិនខានឡើយ ដូចនេះហើយយើងខ្ញុំរងចាំការរិះគន់ក្នុងន័យស្ថាបនា ដោយក្តីសោមនស្សយ៉ាងក្រៃលែង។

ជាចុងបញ្ចប់យើងខ្ញុំ សូមគោរពជូនពរដល់លោកគ្រូ និងមិត្តអ្នកអានទាំងអស់ ដែលបានយក ចិត្តទុកដាក់តាមដាននូវស្នាដៃរបស់យើងខ្ញុំនេះ សូមឲអ្នកទាំងអស់គ្នា ជួបតែ សំណាងល្អគ្រប់ពេលវេលា គ្រប់ទីកន្លែង។

# សណ្ឋានដីប្រទេសកម្ពុជា

## សេចក្តីផ្តើម

ប្រទេសកម្ពុជាស្ថិតនៅភូមិភាគអាស៊ីអាគ្នេយ៍ ចន្លោះខ្សែស្របទី 10° និងទី 15° នៃរយៈទទឹងខាងជើង និងចន្លោះខ្សែបណ្តោយទី 102° និងទី 108° នៃរយៈបណ្តោយខាងកើត មានផ្ទៃដី 181 035km² គឺមានទំហំតូចជាងបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ លើកលែងតែប្រទេសព្រុយណេ សិង្ហបុរី និង ទីម័រខាងកើត ។

ប្រទេសកម្ពុជាមានរាជធានីចំនួន 1 គឺរាជធានីភ្នំពេញ មានខេត្តចំនួន 25 ស្រុកចំនួន 159 ខណ្ឌ ចំនួន 12 ក្រុងចំនួន 26 ឃុំចំនួន 1417 សង្កាត់ចំនួន 204 និងភូមិចំនួន 14073 (ចំនួនភូមិផ្លូវការរបស់ * ក្រសួងមហាផ្ទៃ 13 852 ភូមិ) ។ តាមលទ្ធផលជំរឿនចុងក្រោយនាខែមីនា ឆ្នាំ 2008 ប្រជាជនកម្ពុជា មានចំនួនសរុប 13 395 682 នាក់ បច្ចុប្បន្នមានប្រហែល 15 458 332 នាក់ (ឆ្នាំ 2014) ។ចំនួននេះគឺតិចជាង បើធៀបទៅនឹងចំនួនប្រជាជននៃបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ លើកលែងតែប្រទេសឡាវ ព្រុយណេ សិង្ហបុរី និងទីម័រខាងកើត ។កម្ពុជាស្ថិតក្នុងមណ្ឌលត្រូពិចម៉ូសុងមានអាកាសធាតុក្តៅហើយសើម ដែលបង្កើតបានជារដូវពីរគឺ រដូវប្រាំង និងរដូវវស្សា។ កម្ពុជាមានព្រំប្រទល់ប៉ែកខាង ជើងជាប់ទៅនឹង ប្រទេសថៃនិងឡាវ ប៉ែកខាងកើតជាប់ទៅនឹងប្រទេសវៀតណាម ហើយប៉ែកខាង លិចជាប់ទៅនឹងឈូងសមុទ្រថៃ។នៅតាមតំបន់ជនបទភាគច្រើនគ្របដណ្តប់ដោយព្រៃឈើ។ បឹង ដែលធំជាងគេគឺ បឹងទន្លេសាប ដែលជាបឹងដែលសំបូរត្រីជាងគេបំផុត ហើយទន្លេដែលវែងជាងគេ គឺ ទន្លេមេគង្គដែលយើងអាចធ្វើដំណើរតាមនាវាពីភាគខាងជើងរហូតដល់ភាគខាងត្បូងនៃផ្ទៃប្រទេស។ម៉្យាងវិញទៀតទន្លេមេគង្គជាទន្លេដែលជាប់ចំណាត់ថ្នាក់លេខ ១២ ក្នុងចំណោមទន្លេ ដែលវែងជាងគេបំផុតនៅលើពិភពលោក។

# មាតិកា


I. លក្ខណៈទូទៅនៃសណ្ឋានដីប្រទេសប្រទេសកម្ពុជា ........................ 1

II. ការបែងចែកសណ្ឋានដី ........................................................ 1

១. តំបន់មាត់សមុទ្រ ............................................................... 1

២.តំបន់ខ្ពង់រាប ...................................................................... 4

៣.តំបន់ទំនាបកណ្ដាល ............................................................ 5

៤.តំបន់ប្រជុំភ្នំ ........................................................................ 7

៥. តំបន់ភ្នូនភ្នំ ...................................................................... 10

III. សេចក្ដីសន្និដ្ឋាន ............................................................. 12

IV. ឯកសារយោង .................................................................. 14

## I. លក្ខណៈទូទៅនៃសណ្ឋានដីប្រទេសប្រទេសកម្ពុជា

### លក្ខណៈទូទៅ

លក្ខណៈទូទៅនៃសណ្ឋានដីប្រទេសកម្ពុជាមានផ្ទៃផតកណ្តាល ព័ទ្ធស្ទើរជុំវិញទៅដោយភ្នំ និងខ្ពង់រាប ហើយតំបន់ខ្ពង់រាបនេះដែលគឺសម្បូរទៅដោយព្រៃឈើ សត្វព្រៃ រ៉ែនិងប្រភពទឹកជាច្រើន។មិនតែប៉ុណ្ណោះតំបន់ទំនាបកណ្តាលក៏មានសារៈសំខាន់ណាស់ដែរសម្រាប់វិស័យកសិកម្មរបស់ប្រទេសកម្ពុជា។នៅប៉ែកនិរតី ផ្ទៃដីមានរាងទេរចុះពីជួរភ្នំក្រវាញសំដៅទៅឈូងសមុទ្រដែលជាទីសម្បូរកូនកោះ។

លក្ខណៈភូមិសាស្ត្ររបស់ស្រុកខ្មែរអាចចែកជាពី តំបន់ដាច់ពីគ្នាគឺ តំបន់ភ្នំខ្ពង់រាបស្ថិតនៅ ភាគខាងជើងភាគឦសាន និង ភាគនិរតីនៃប្រទេស។ ចំណែកខាងតំបន់វាលទំនាបវិញ គឺ ស្ថិតតាម បាតខ្ទះភាគកណ្តាល តំបន់បឹងបួវាលទំនាប ទន្លេមេគង្គ និង តំបន់មាត់សមុទ្រ។ មួយភាគធំនៃ ផ្ទៃ ប្រទេសត្រូវគ្របដណ្តប់ទៅដោយសម្បត្តិធម្មជាតិ ព្រៃឈើ ហើយ តំបន់ដីខ្ពស់ គឺខ្ពង់រាបហាក់មាន លក្ខណៈជាខ្សែក្រវាត់ធម្មជាតិដែលហ៊ុមព័ទ្ធ វាលទំនាប របស់ប្រទេសខ្មែរទាំងមូល។

## II. ការបែងចែកសណ្ឋានដី

គេបែងចែកសណ្ឋានដីប្រទេសកម្ពុជាជា បួនតំបន់សំខាន់ៗដូចជា តំបន់មាត់សមុទ្រ តំបន់ខ្ពង់រាប តំបន់ទំនាបកណ្តាល និងតំបន់ប្រជុំភ្នំ។

### ១. តំបន់មាត់សមុទ្រ

មួយភាគប្រាំមួយនៃប្រទេសខ្មែរជាឆ្នេរសមុទ្រប្រវែង៤៥៥គមដែលជាឆ្នេរនៃសមុទ្រតែមួយគឺ ឈូងសមុទ្រថៃ ។

#### ក. ឆ្នេរសមុទ្រខ្មែរ

មានកោះពីរយ៉ាងដាច់ពីគ្នាដោយឡែក ឆកកំពង់សោមគឺស្មើរកោះស្នាច់និងស្មើរកោះវាលរេញ ។ឆ្នេរសមុទ្រខ្មែរមិនសូវជ្រៅប៉ុន្មានទេដោយមាន ជម្រៅទឹក មធ្យមមិនហួសពី ៥៦មជាហេតុនាំឲ្យមានលទ្ធភាពជាច្រើនក្នុងការពង្រីកសកម្មភាពនៅតាមសមុទ្រ ។នៅតាមឆ្នេរសមុទ្រនេះ ហើយដែលរដ្ឋាភិបាលស្ថាបនាកំពង់ផែ យ៉ាងល្អពីរគឺកំពង់ផែរាម និងកំពង់ផែកំពង់សោម។ទីក្រុងកែបដែលស្ថិតនៅតាមឆ្នេរសមុទ្រនេះដែរជា បុរីទេសចរណ៍ទំនើបមួយប្រកបដោយ សោភណភាពយ៉ាងប្រសើរ។គេអាចចែកឆ្នេរសមុទ្រខ្មែរ ជាប្រាំផ្នែកពីពាយ័ព្យទៅអាគ្នេយ៍ ៖

- **ពីចាំយាមទៅព្រែកគគីរ**

ពីព្រំប្រទល់ថៃត្រង់ ចាំយាមទៅទល់ព្រែកគគីរឆ្នេរសមុទ្រតំបន់នោះទាបប្រកបទៅដោយ ភក់និងព្រៃកោងកាង។នៅទីនោះមានភូមិច្រើនដែលជាភូមិអ្នកនេសាទដូចជាថ្នល់ក្របី បឹងក្រសោប កោះចៅលាវ កោះកាពិ ។ល។រីឯទីតាំងមណ្ឌលស្រុកកោះកុងគឺកោះមូលដែលជាកោះមួយដុះភ្ជាប់មកដីគោកដោយសារទំនប់ផែ ។

- **ពី ព្រែកគគីរទៅជ្រោយសូរិយាវង្ស**

ពីព្រែកគគីរទៅទល់ជ្រោយសូរិយាវង្ស ឆ្នេរសមុទ្រស្ថិតនៅក្បែរជើងភ្នំនិងនៅចំផ្លូវខ្យល់មូសុង គឺ ជាឆ្នេរប្រកបទៅដោយ ថ្មនិងមានរាងរឆិញរឆុញ។ប៉ុន្តែផ្ទាំងថ្មធំៗពុំសូវសម្បូរទេមានតែ ជ្រោយខ្លះដែលជាជម្រកនៃ ឆកសមុទ្រនិង ដើមស្វាវដុះតាមឆ្នេរដូចជាជ្រោយយាយសែន ជ្រោយស្នាច់និងជ្រោយសូរិយាវង្ស ។

- **ឆកកំពង់សោម**

ឆកកំពង់សោមព័ទ្ធពីក្រៅដោយកោះ ភ្នំមួយជួរ។ទីនេះសម្បូរ ព្រៃតែគ្មានមនុស្សរស់នៅទេ។ នៅខាងកើត និងខាងលិចឆកនេះមានជ្រោយ សូរិយាវង្សនិងជ្រោយថ្មសដែលមានភូមិអ្នកនេសាទចម្លងគោនិងជ្រោយវាលរេញដែលមានកំពង់ផែកំពង់សោម ។

ទិដ្ឋភាពទូទៅនៃឆកកំពង់សោមប្រសើរណាស់ ព្រោះឆកនេះបែរមុខចំខ្យល់មូសុងរស្សាពីទិសនិរតី។ ម្យ៉ាងទៀតឆកនេះឆាប់គោកបន្តិចម្តងៗ ដោយសារល្បាប់ដីជាច្រើនដែលទឹកព្រែកទាំងឡាយនាំចូលមក ។

➢ **ពីកំពង់សោមដល់ឆកទឹកសាប**

ពីក្រុងព្រះសីហនុទៅដល់ឆកទឹកសាបមានឆ្នេរខ្សាច់ជាច្រើនប្រកបទៅដោយដើមស្វាវដុះឆ្លាស់គ្នានឹង ដុំថ្ម។នៅចំកណ្តាលវាលឆ្នេរនេះ មានឆករាបជាជម្រកយ៉ាងសំខាន់សម្រាប់កំពង់ផែរាម ដែលគេចផុតពីខ្យល់មូសុង ។

➢ **ពីឆកទឹកសាបទៅហាទៀង**

ពីឆកទឹកសាបទៅហាទៀង (ប្រទេសវៀតណាម)មាត់សមុទ្រមានរាងផតចូលក្នុងដោយសារឆកទឹកសាបនិង ឆកវាលរេញដែលមានឆ្នេរទាបហើយពោរពេញទៅដោយភក់។បន្ទាប់ពីឆកទាំងពីរនេះក្បែរជើងឆ្នេរចោតនៃភ្នំបូកគោមាន ឆ្នេររាងជងធ្នូប្រកបដោយដើមកោងកាង ។ ខាងកើតពាមសមុទ្រនៃស្ទឹងកំពតឆ្នេរនៅតែទាបលើកលែងតែជ្រោយកែបដែលមានស្ថានីយងូតទឹកនោះចេញ ។

**ខ. ឈូងសមុទ្រថៃ**

ឈូងសមុទ្រថៃ ជាសមុទ្រមួយពុំសូវជ្រៅ ហើយមានបាតរាបស្មើ ។ ឈូងសមុទ្រនេះផ្តាច់ប្រទេសខ្មែរពីឧបទ្វីបម៉ាឡាកា កោះសូម៉ាត្រា និងកោះជ្វា ។ គឺជាជាយទ្វីបដែលមានជម្រៅមធ្យម ១០ ម ហើយជម្រៅអតិបរមាមិនដល់ ៧៥ ម ឡើយ ។

**គ. កោះទាំងឡាយនៃឈូងសមុទ្រថៃ**

ក្រុមកោះនៅខាងជើងពៀបសមុទ្រព្រែកតាគី ជាកោះកើតឡើងដោយសម្រុតសមុទ្រនៃតំបន់នោះ ដូចជា កោះពរ កោះកាពិ កោះថៅលាវ កោះស្តេត ។

- **កោះកុង** ជាកោះធំជាងគេនៅប្រទេសខ្មែរ (ប្រហែល **៨០ គម²**) គឺជាកូនភ្នំមួយកម្ពស់ ៤១០ ម ដែលដាច់ចេញពីទ្វីបដោយសារបំណាក់ភ្នំភ្លើង ។

## ២.តំបន់ខ្ពង់រាប

ទំនាបកណ្តាលប្រទេសខ្មែរត្រូវបានព័ទ្ធជុំវិញទៅដោយជួរភ្នំ និងខ្ពង់រាបជាច្រើន ដូចជាខ្ពង់រាបខាងជើង ខ្ពង់រាបខាងកើត និងឦសាន ។

ខ្ពង់រាបខាងជើងជាខ្ពង់រាបប្រកបទៅដោយល្បាប់ចាស់ ឆ្លាស់គ្នានឹងថ្មបាយក្រៀម និងជាតំបន់ព្រៃរបោះ។ខ្ពង់រាបនេះស្ថិតនៅត្រង់ខេត្តបាត់ដំបងខេត្តសៀមរាប និងខេត្តកំពង់ធំ គឺ ភ្ជាប់ទំនាបកណ្តាលទៅជួរភ្នំដងរែក ។ នៅតាមទ្រនុងកណ្តាលនៃខ្ពង់រាបនេះមានកូនភ្នំដាច់ៗពីគ្នាដូចជា ភ្នំស្វាយចេក ភ្នំកំបុត ភ្នំចុងកាល់ ភ្នំត្បែង (៥២៤ ម) ភ្នំគូលែន (៤៩៦ម) ភ្នំរយោង (៤៣៣ ម)។

### ក.ខ្ពង់រាបខាងកើត និងឦសាន

**ខ្ពង់រាបខេត្តស្ទឹងត្រែង និងក្រចេះ** មានលក្ខណៈដូចគ្នានឹងខ្ពង់រាបខាងជើងដែរ ហើយនៅដាច់ពីខ្ពង់រាបនោះដោយសារជ្រលងនៃទន្លេមេគង្គ គឺជាតំបន់មានរាងតុជាតំបន់ល្បាប់ ចាស់ប្រកបទៅដោយព្រៃរបោះ តែនៅទីនោះពុំសូវសម្បូរកូនភ្នំដាច់តែឯងទេ ។

**ខ្ពង់រាបខេត្តកំពង់ចាម** ជាខ្ពង់រាបមួយយ៉ាងទេរទៅឦសាន ហើយមានរយៈកម្ពស់ ២០០ ម ខាងលិចនិរតីជាប់នឹងទំនាបកណ្តាល ។ ខ្ពង់រាបទាំងនោះក៏មានរាងតុ និងប្រកបទៅដោយ ល្បាប់ចាស់ និងថ្មបាសាល់ ដែលមានស្រទាប់លើពុកជាដីក្រហមទៅហើយ ។ ទីនោះដែលមាន ទួលថ្មបាសាល់ចំនួនបួនគ្របពីលើថ្មក្រែ បានក្លាយជាចម្ការដំណាំធំៗដូចជាៈ ចម្ការលើ មេមត់ និង ស្នួល ។ តំបន់ដីក្រហមទាំងនោះសុទ្ធសឹងជាចម្ការកៅស៊ូ និងចម្ការដំណាំធំៗ ។

**ខ្ពង់រាបខេត្តរតនគិរី** ជាគែមខាងលិចនៃប្រជុំភ្នំកភ្នំនៃប្រទេសវៀតណាមកណ្តាល។ខ្ពង់រាបនេះដាច់ជាច្រើនផ្នែកដោយដៃទន្លេមេគង្គ ។ នៅចន្លោះទន្លេសាន និងទន្លេស្រែពក មាន ខ្ពង់រាបកែវ ដែលជាខ្ពង់រាបថ្មបាសាល់ គ្របដណ្តប់ដោយរីយ៉ូលីត ហើយមានកំពូលខ្ពស់បំផុតមិន ហួសពី ៥០០ ម រីឯច្រាំងខ្ពង់រាបនេះ ជាថ្មគ្រីស្តាឡាំង ។ នៅចន្លោះទន្លេកុង និងទន្លេសាន ប្រជុំភ្នំ មួយដែលមានកម្ពស់មធ្យមស្ថិតជាព្រំប្រទល់រវាងប្រទេស ខ្មែរ និងប្រទេសឡាវ ។ ភ្នំដែលមាន កំពូលខ្ពស់លើសពី ៧០០ ម គឺភ្នំពោងពាយ (៨១៦ ម) ភ្នំត្រង់ (៨១២ ម) ភ្នំរាំង (៧០១ ម) ។

**ខ្ពង់រាបមណ្ឌលគិរី និងខ្ពង់រាបឆ្លូងលើ** ជាខ្ពង់រាបដែលមានរយៈកម្ពស់ចុះជាលំដាប់ពី អូររាំង (៩០០ម) ទៅគ្រប់ទិស (៥០០ម) ។ កំពូលខ្ពស់បំផុតគឺ ភ្នំព្រះបាទ (ភ្នំណាមលៀ) ដែលមាន កម្ពស់ ១ ១០៣ ម ។ ខ្ពង់រាបនេះមានមួយភាគធំគ្របដណ្តប់ដោយដីក្រហម ក្លាយមកពីថ្មបាសាល់ និងថ្មបាយក្រៀម គឺជាឃ្លាំងទឹកមួយពិតប្រាកដជាប្រភពនៃផ្លូវទឹកនានាដែលហូរចាក់មកទន្លេមេគ ង្គ។ ហើយនៅចន្លោះរយៈកម្ពស់ ៧០០ ម និង៤០០ ម មានសុទ្ធតែព្រៃរបោះ។

## ៣.តំបន់ទំនាបកណ្តាល

តំបន់ទំនាបកណ្តាល ជាផ្នែកកណ្តាលមួយនៃប្រទេសខ្មែរ ជាទំនាបមួយយ៉ាងធំដែលមានរយៈកម្ពស់មធ្យមតិចជាង ៥០ម (ពី២០ម ទៅ ៣០ម) និងមានចំណោតខ្សោយបន្តិចម្តងៗពីជើងទៅត្បូង។គឺជាទំនាបមួយយ៉ាងរាប ប្រកបដោយចំណោតខ្សោយ (១%) និងជាទំនាបល្បប់យ៉ាងធំសង្ខាងបឹងទន្លេសាប និងសង្ខាងទន្លេមេគង្គពីពាយ័ព្យទៅអាគ្នេយ៍ ហើយទំនាបនេះកាន់តែរីកធំឡើងសំដៅទៅប្រទេសវៀតណាមខាងត្បូង ។

ទំនាបកណ្ដាលនេះ ប្រកបទៅដោយល្បប់ចាស់ត្រង់ជាយខាងក្រៅ និងល្បាប់ថ្មីត្រង់តំបន់ក្បែរផ្លូវទឹក គឺជាតំបន់មានដីជាតិយ៉ាងល្អ និងមានដង់ស៊ីតេប្រជាជនខ្ពស់ ។ ម្យ៉ាងទៀតទំនាបនេះចែកជា ៤ ភូមិភាគ ៖

**ក. ភូមិភាគល្បប់ម៉ដ្ឋ**

ភូមិភាគល្បប់ម៉ដ្ឋ ដែលមានទទឹងប្រវែងពីបួនដប់ម៉ែត្រដល់ច្រើនរយម៉ែត្រ គឺជាតំបន់ច្រាំងទន្លេ និងជាយកោះ។ ហើយដីនោះជាដីល្អសម្រាប់ដំណាំកប្បាស មន ថ្នាំ ជក់ និងត្រុំ ។ ម្យ៉ាងទៀតភូមិភាគនេះជាទីប្រជុំជនយ៉ាងកុះករ និងសម្បូរទៅដោយផ្លូវថ្នល់ ។

**ខ. ភូមិភាគលិចទឹក និងវាលភក់**

ភូមិភាគលិចទឹក និងវាលភក់ ព័ទ្ធពីក្រៅតំបន់ល្បប់ម៉ដ្ឋ ហើយមានដីជាតិល្មមគួរសមដែរ ។ រីឯប្រជាជនក៏មានច្រើន ដោយសារបឹងមានត្រីច្រើន ដោយសារដំណាំពោត ល្ង ឈូក ។ល។ ម្យ៉ាងទៀតព្រៃលិចទឹកនៃបឹងទន្លេសាបជាកន្លែងត្រីពង និងជាកន្លែងត្រីធំធាត់ដ៏សន្ធឹកសន្ធាប់ ។ ហេតុនេះហើយ បានជាបឹងធំក្លាយជាមជ្ឈមណ្ឌលនេសាទមួយយ៉ាងសំខាន់នៃប្រទេសខ្មែរ ។

**គ. វាលស្រែ**

វាលស្រែ ដែលនៅខាងក្រៅតំបន់លិចទឹក មានដីជាតិតិចជាងច្រាំងទន្លេ គឺជាតំបន់ដែលបំពេញមុខងារយ៉ាងសំខាន់ក្នុងវិស័យកសិកម្ម ។ វាលស្រែទាំងនោះមានផ្ទៃធំធេងដាច់កន្ទុយភ្នែក នៅខេត្តបាត់ដំបង កំពង់ធំ តាកែវ ព្រៃវែង កំពង់ចាម និងស្វាយរៀង ។

### ឃ. ភ្នំតូចៗ

នៅលើវាលទំនាបកណ្តាលនេះ គេឃើញមានភ្នំតូចៗដាច់តែឯងនៅឯនេះមួយនៅឯនោះមួយ គឺសុទ្ធតែភ្នំថ្មក្រែ ដូចជា ភ្នំបាទី នៅខេត្តតាកែវ ភ្នំបាភ្នំ នៅខេត្តព្រៃវែង ភ្នំបាធាយ នៅខេត្តកំពង់ចាម ភ្នំក្រោម នៅខេត្តសៀមរាប ភ្នំនាងកង្រី នៅខេត្តកំពង់ឆ្នាំង ។

ទំនាបកណ្តាលនៃប្រទេសខ្មែរព័ទ្ធជុំវិញដោយភ្នំ និងខ្ពង់រាប គឺភ្នំក្រវាញ នៅនិរតី ភ្នំដងរែក នៅខាងជើង ខ្ពង់រាបខាងជើង ខ្ពង់រាបខាងកើត និងព្ស៊ាន ។

## ៤.តំបន់ប្រជុំភ្នំ

### ក. ជួរភ្នំក្រវាញ

ជួរភ្នំក្រវាញចែកពីលិចទៅកើតជា ភ្នំក្រវាញខាងលិច ភ្នំក្រវាញកណ្តាល និងភ្នំក្រវាញខាងកើត។គឺជាជួរភ្នំដែលសណ្ដូកតាំងពីខាងជើងខេត្តចន្ទបូរនៃប្រទេសថៃដល់ខេត្តកំពត គឺពីទិសពាយ័ព្យទៅទិសអាគ្នេយ៍ ។ ហើយបាតភ្នំទាំងនោះ សុទ្ធសឹងប្រកបទៅដោយថ្មក្រានីត គ្របដណ្តប់ពីក្រៅដោយថ្មក្រែល្បាយខ្សាច់យ៉ាងក្រាស់។ម្យ៉ាងទៀតសំណឹកបានផ្ដាច់ជួរភ្នំនេះជាខ្ពង់រាបប្រកបដោយមុខចំណោត ឬជាភ្នំដាច់ពីគ្នា ។ គឺនៅតំបន់នេះហើយដែលមានកំពូលភ្នំខ្ពស់ជាងគេ «ភ្នំឱរ៉ាល់» មានកម្ពស់ ១.៨១៣ ម ។ នៅតំបន់ភ្នំនេះ គេពុំទាន់ធ្វើការរុករកទេ ព្រោះជាតំបន់ប្រកបទៅដោយព្រៃក្រាស់ចូលមិនចុះ ។ ទីនេះ មានបណ្តាជនរស់នៅយ៉ាងស្តួចស្តើងគឺ ពួកព័រ ពួកស្អូច ។តែសំណង់ផ្លូវភ្នំក្រវាញជាទ្វារចំហរសម្រាប់សម្រួលការទាក់ទងជាមួយនឹងតំបន់ដទៃ ។ ជុំវិញភ្នំក្រវាញមានតំបន់មួយដែលមានរយៈកម្ពស់មធ្យម និងមានកូនភ្នំដាច់ៗពីគ្នាដែលមានកំពូលដល់ទៅ ៨០០ ម ។ តំបន់នេះភ្ជាប់ជួរភ្នំក្រវាញទៅសមុទ្រមួយ

ផ្នែក ហើយមួយផ្នែកទៀតភ្ជាប់ជួរភ្នំក្រវាញទៅទំនាបកណ្ដាល ។ ម្យ៉ាងទៀត នៅតំបន់នេះមានអ្នកស្រុករស់នៅតែត្រង់វាលទំនាប និងជ្រលងមានជីជាតិ ។

❖ **ភ្នំក្រវាញខាងលិច**

សណ្ដូកពីប៉ៃលិនដល់ស្ទឹងពោធិ៍សាត់ គឺជាភ្នំប្រកបទៅដោយថ្មក្រាម និងថ្មស៊ីសលាយក្រែ ដែលមានពើងផ្នត់យ៉ាងខ្លាំង ។ កំពូលភ្នំសំខាន់ៗនៃតំបន់នេះមាន ភ្នំសពុក(៨៩៣ ម) ភ្នំតាជិត (១.១១៤ ម) ភ្នំទឹកព្រិល (១.១២៣ ម) ភ្នំធំ (១.២៥៨ ម) ភ្នំមូស (១.៣៣៧ ម) ភ្នំខ្មោច (១.៤២៥ ម) និងភ្នំទំពរ ខ្ពស់ជាងគេនៅទីនោះ (១.៥៦៣ ម) ។

❖ **ភ្នំក្រវាញកណ្ដាល**

ជាប្រជុំភ្នំមួយដ៏ធំ ដែលមានផ្ទៃរាងទេរពីមោងទៅកោះកុង ។ ប៉ែកខាងលិចមាន ភ្នំសំកុះ (១.៧៤៤ម) ក្បែរឈូងសមុទ្រថៃ។ ខាងកើតមានភ្នំជាច្រើនដែលមានរយៈកម្ពស់លើសពី ១.០០០ ម ដូចជា ភ្នំប៉ាន (១.៤០០ម) ភ្នំបាកាន (១.២២០ម) និងភ្នំខ្នងត្រពាំង (១.១៧២ ម) ។

❖ **ភ្នំក្រវាញខាងកើត**

**ចែកជាបីក្រុមយ៉ាងច្បាស់ ៖**

- **ប្រជុំភ្នំខ្យល់ នៅចន្លោះខេត្តពោធិ៍សាត់ និងខេត្តកំពង់ស្ពឺ** គឺនៅខាងលិចខេត្តកំពង់ឆ្នាំង។ គឺនៅទីនេះហើយដែលមានភ្នំខ្ពស់ជាងគេនៃប្រទេសខ្មែរ ឬភ្នំឱរ៉ាល់ (១.៨១៣ម) ។
- **ប្រជុំភ្នំអូរម្លូ នៅចន្លោះស្រែអំបិល និងខេត្តកំពង់ស្ពឺ** ហើយកំពូលខ្ពស់បំផុតប្រហែលជា ១.០០០ ម ដូចជា ខ្ពង់រាបគិរីរម្យ (៧០០ ម) ជាដើម ។

- **ប្រជុំភ្នំដំរី នៅជាប់ពីភ្នំអូរម្លូដោយច្រកពេជ្រនិល** ដែលកាត់ដោយផ្លូវជាតិលេខ ៤ គឺផ្លូវពីភ្នំពេញទៅក្រុងព្រះសីហនុ ។ ហើយពីខាងត្បូងប្រជុំភ្នំនេះបញ្ចប់ដោយមុខចំណោតនៃភ្នំបូកគោ(១.០៧៥ ម) ។

## ខ. ជួរភ្នំដងរែក

ជួរភ្នំដងរែកសណ្ដូកពីខាងកើតទៅខាងលិច គឺពីជ្រលងទន្លេមេគង្គទៅជ្រលងទន្លេចៅប្រះយ៉ា ឬទន្លេមេណាមនៃប្រទេសថៃ ។ តាមពិត ដងរែកមិនមែនជាជួរភ្នំទេ តែជាគែមខាងត្បូងនៃខ្ពង់រាបនគររាជ ដែលស្ថិតក្នុងភូមិភាគខាងកើតនៃប្រទេសថៃ គឺជាជញ្ជាំងថ្មក្រៃ និងជាមុខចំណោតមួយយ៉ាងវែង បណ្ដោយប្រហែល ៣០០ គម និងមានរយៈកម្ពស់ចុះជាលំដាប់ពីខាងកើតទៅខាងលិច (គឺពី ៧០០ ម ទៅ ២០០ ម) ។

ជួរភ្នំដងរែកមានមុខចំណោតខាងលើខ្ពង់រាបខ្មែរខាងជើង តែមានចំណោតយ៉ាងទេរទាបទៅខាងប្រទេសថៃ ។ ការដែលមានចំណោតសង្ខាងមិនស្មើគ្នាដូច្នេះ ជាការបញ្ជាក់ឲ្យឃើញថា ទំនាបខ្មែរ និងទំនាបថៃ មានរយៈកម្ពស់ខុសគ្នាយ៉ាងសម្បើម គឺពី ៥០ ទៅ ១៥០ ម នៅប្រទេសខ្មែរ និងពី ១០០ ទៅ ៣០០ ម នៅប្រទេសថៃ ។ ពីខាងកើតទៅខាងលិច កំពូលខ្ពស់ជាងគេមាន ៖ ភ្នំដងរែក(៧៥៦ ម) ជាកំពូលខ្ពស់បំផុត ភ្នំព្រះវិហារ (៦២៥ ម) ភ្នំអណ្ដូងស្វាយ (៤៥៧ ម) ភ្នំម៉ាកកែ (៥៣៧ ម) ។ នៅចន្លោះភ្នំមានច្រកដែលសម្រួលការទាក់ទងរវាងភូមិភាគថៃខាងកើត និងទំនាបកណ្ដាលនៃប្រទេសខ្មែរ ។ ច្រកសំខាន់ៗគឺ ច្រកអន្សេ ច្រកដូនតាប៉ាយ ច្រកដូនឪ ច្រកតាព្រហ្ម និងច្រកកូន ។

## ៥. តំបន់ភ្នំ

នៅតំបន់នេះមានអ្នកស្រុករស់នៅតែត្រង់វាលទំនាប និងជ្រលងមានជីជាតិ ។ រីឯតំបន់ខ្ពស់សុទ្ធសឹងប្រកបទៅដោយព្រៃ ។ គេអាចចែកតំបន់នោះជាប្រាំមួយផ្នែក ៖

### ក.តំបន់មាត់សមុទ្រ

តំបន់មាត់សមុទ្រជាទំនាបដែលមានរយៈកម្ពស់កើនយ៉ាងរហ័សពីសមុទ្រទៅទល់ជើងភ្នំក្រវាញ ។ ទំនាបនេះទាក់ទងជាមួយនឹងទំនាបកណ្ដាលពីជើងទៅត្បូងតាមច្រក ៣ ៖ ពីតំបន់មោងទៅកោះកុង តាមច្រកវាលវែង ពីតំបន់ពោធិ៍សាត់ទៅស្រែអំបិល តាមច្រកតាសី និងពីកំពង់ស្ពឺទៅស្រែអំបិល តាមច្រកពេជ្រនិល ។ តំបន់នេះសម្បូរកូនភ្នំដែលជួនកាលជាកូនភ្នំនៅកណ្ដាលទំនាប ដូចជា ភ្នំជំនាប វាលេញ ហើយជួនកាលទៀត ជាកូនភ្នំលេចពីសមុទ្រដែលជាកោះ ដូចជា កោះកុង(ខ្ពស់ដល់ទៅ ៤១០ ម) ។

### ខ. តំបន់កូនភ្នំខាងលិចខេត្តបាត់ដំបង

តំបន់កូនភ្នំខាងលិចខេត្តបាត់ដំបងដែលសន្ធឹងពីអូរជ្រៅទៅមោង មានកូនភ្នំប្រកបដោយរាងប្លែកៗ ដែលមានកំណើតពីថ្មច្រើនបែបគឺ ថ្មគ្រីស្តាឡាំង និងថ្មក្រៃ (ភ្នំវែង) ថ្មក្រៃ និងថ្មស៊ីស (ភ្នំរន្ទា ភ្នំម៉ាកហឿន) ថ្មកំបោរ (ភ្នំសំពៅ ភ្នំសិរីសោភ័ណ) ។

### គ. តំបន់កូនភ្នំចន្លោះខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង

តំបន់កូនភ្នំចន្លោះខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំងជាខ្ពង់រាបល្បាប់ចាស់មួយដែលមានកូនភ្នំច្រើន ដូចជា កូនភ្នំថ្មក្រៃ កំរែង ក្បែរខេត្តពោធិ៍សាត់ និងកូនភ្នំថ្មភ្នំភ្លើង ក្រាំងលាវ ក្បែរខេត្តកំពង់ឆ្នាំង ។

## ឃ. ខ្ពង់រាបខេត្តកំពង់ស្ពឺ

ខ្ពង់រាបខេត្តកំពង់ស្ពឺ មានរយៈកម្ពស់ឡើងជាលំដាប់ពីទំនាបកណ្ដាលទៅជួរភ្នំក្រវាញ ហើយមានប្រជុំភ្នំទាំងអស់ចំនួនបីៈ ភ្នំជំរាយ នៅខាងល្វាសាន ភ្នំពិល ភ្នំក្រោល ភ្នំព្រះ នៅចំកណ្ដាល ហើយប្រជុំភ្នំរាជីគង នៅចុងបំផុត ។

## ង. តំបន់កូនភ្នំចន្លោះខេត្តកំពង់ស្ពឺ និងខេត្តកំពត

តំបន់កូនភ្នំចន្លោះខេត្តកំពង់ស្ពឺ និងខេត្តកំពត ជាខ្ពង់រាបខ្សាច់មានផ្ទៃចេះតែរួមទៅខាងត្បូង និងប្រកបទៅដោយប្រជុំភ្នំសំខាន់ៗបីៈ ភ្នំចង្អោរ (៧២២ ម) ភ្នំព្រះ (៧៨០ ម) និងភ្នំទ្វារ ។

## ច. តំបន់កូនភ្នំចន្លោះខេត្តកំពត និងខេត្តតាកែវ

តំបន់កូនភ្នំចន្លោះខេត្តកំពត និងខេត្តតាកែវ ជាខ្ពង់រាបមួយដ៏ទាប និងប្រកបទៅដោយកូនភ្នំកម្ពស់ពី ១០០ ទៅ ៣០០ ម ដូចជា កូនភ្នំកែប ភ្នំថ្មកំបោរនៅស្រុកកំពង់ត្រាច និងស្រុកទូកមាស ហើយនិងប្រជុំភ្នំបាក់នឹម នៅតានី ជាដើម ។

## III. សេចក្តីសន្និដ្ឋាន

ដូចដែលបានរៀបរាប់ខាងលើមក យើងអាចសន្និដ្ឋានបានថា ប្រទេសកម្ពុជាយើងជាប្រទេសមួយដែល អំណោយផលល្អពីធម្មជាតិ ទាំងសណ្ឋានដី ទាំងអាកាសធាតុ ដែលជាចំណែកដ៏ធំក្នុងការជួយឲ្យប្រទេសជាតិមានការអភិវឌ្ឍនិងរីកចម្រើន។ ព្រោះប្រទេសយើងមានអាកាសធាតុល្អ និង ដីពោពេញ ដោយដីមានជីជាតិ ហើយសម្បូរទំនាបដែលព័ទ្ធជុំវិញទៅដោយប្រជុំភ្នំ និង ដោយខ្ពង់រាប ដែលមិនសូវខ្ពស់ ព្រោះមានភ្នំនៅតាមបរិវេណដែលមិនជាឧបសគ្គដល់ចរាចរណ៍ និងការ ដឹកជញ្ជូនឡើយ។ តំបន់ទំនាបនេះបានផ្តល់សារៈសំខាន់ណាស់ ដល់ការដាំដុះលើវិស័យ កសិកម្ម និង ដំណាំឧស្សាហកម្មផ្សេងៗ ។ ចំណែកតំបន់ខ្ពង់រាប និងតំបន់ភ្នំជាតំបន់មួយ ដែលសំម្បូរទៅដោយធនធានធម្មជាតិជាច្រើនដូចជា ធនធានរ៉ែ ព្រៃឈើ សត្វព្រៃ និងដីក្រហមដែលអនុគ្រោះដល់ការដាំដុះដំនាំ ឧស្សាហកម្ម គឺ ដំណាំកៅស៊ូ ដែលជាមុខព្រួញ ក្នុងការអភិវឌ្ឍប្រទេស។ រីឯ តំបន់ឆ្នេរក៏ជាតំបន់សេដ្ឋកិច្ចមួយយ៉ាងសំខាន់ ព្រោះលក្ខណៈ សម្បត្តិធម្មជាតិដ៏ល្អប្រសើរនៃតំបន់មាត់សមុទ្រអនុគ្រោះច្រើនដល់ការអភិវឌ្ឍសេដ្ឋកិច្ច ជាតិដូចជាដំណាំចំការធំៗ រោងចក្រឧស្សាហកម្ម សកម្មភាពកំពង់ផែ ទេសចរណ៍ នេសាទ និងទំនាញយករ៉ែ។ ហើយចំណែកអាកាសធាតុមានសារៈសំខាន់ចំពោះវិស័យសេដ្ឋកិច្ចដូច ជា បាននាំទឹកភ្លៀងយ៉ាងច្រើនស្រោចស្រប់ដំណាំវស្សា ដំណាំចំការផ្សេងៗ ផ្តល់កម្តៅ និង ភ្លៀងគ្រប់គ្រាន់ សម្រាប់ការលូតលាស់នៃដំណាំត្រូពិច មាន ធញ្ញជាតិ ស្រូវ ពោត សណ្តែក ដំណាំឧស្សាហកម្ម កៅស៊ូ កប្បាសក្រចៅ ថ្នាំជក់និងបន្លែ ផ្លែឈើច្រើនមុខទៀតដែលមានភាពរីកលូតលាស់ប្រសើរ ។ មូសុងវស្សាបង្កើតឲ្យមានរដូវ ទឹកឡើងដែលផ្តល់ សារៈសំខាន់យ៉ាងច្រើនដល់សេដ្ឋកិច្ច ។ ចំណែកមូសុងប្រាំងបង្ករលក្ខ ណៈប្រសើរដល់ដំណាំរដូវ ប្រាំងគឺដំណាំចំការផ្សេងៗ និង ស្រូវប្រាំងដែលមិនចាំបាច់ត្រូវ ការទឹកភ្លៀង និង បង្ករលក្ខណៈងាយ ស្រួលដល់ការប្រមូលផលរដូវវស្សា ។ធ្វើឲ្យមានរដូវ ទឹកស្រកបង្កភាពងាយស្រួលដល់ការនេសាទ និងឈានទៅរកការអភិវឌ្ឍប្រទេសជាតិ។ មិនតែប៉ុណ្ណោះថែមទាំងមាន ទន្លេ

ធំៗដូចជា ទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ ជាប្រភពទឹកសំខាន់សម្រាប់ប្រើប្រាស់ក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងប្រជាជនប្រើប្រាស់ប្រចាំថ្ងៃ។ ទឹកទន្លេទាំងនេះមានសារៈសំខាន់ដល់ការប្រព្រឹត្តជីវភាពរបស់ប្រជាជន ហើយជួយស្រួលដល់ការដាំដុះដំណាំព្រៃខ្ពស់ ហើយក៏អានជាចំណែកយ៉ាងសំខាន់ក្នុងការធ្វើពាណិជ្ជកម្មក្នុងការនាំចេញនាំចូលនៅផលិតផលល្អៗ និងរកចំណូលចូលក្នុងប្រទេសជាតិ។

## IV. ឯកសារយោង

- https://www.facebook.com/share/1Dwm7F1tcZ/?mibextid=wwXIfr
- ភូមិសាស្ត្រនៃប្រទេសកម្ពុជា | Chouk Khmer
- សៀវភៅសិក្សាសង្គម ភូមិវិទ្យា ថ្នាក់ទី ១២ ក្រសួងអប់រំយុវជន និងកីឡា បោះពុម្ព ឆ្នាំ ២០១០

Thank you